# វិធីការពារកុំឲ្យមានគ្រោះថាក់ដោយសារកាំជ្រួច
(Firework Safety Tips)

យើងច្រើនសប្បាយរីករាយថ្ងៃបុណ្យដោយសារការបាញ់កាំជ្រួច ជា ពិសេសក្នុងការអបអរសាទរបុណ្យឯករាជ្យ 4th July ។ ប៉ុន្តែការកាំជ្រួចនេះអាចធ្វើឲ្យយើងមានគ្រោះ ថ្នាក់ ដូចជារលាកភ្លើង និងរបួសភ្នែកជាដើម។

លំដាប់តទៅនេះ ជាចំណុចខ្លះៗ ចេញពីទីស្នងការការពារគ្រោះថ្នាក់ដោយការប្រើប្រដាប់ឬគ្រឿងផ្សេងៗនៃសហរដ្ឋ ហៅថា U.S. Consumer Product Safety Commission ដើម្បីការពារគ្រោះថ្នាក់ផ្សេងៗ ប្រសិនបើលោក អ្នកមានបំណងចង់អុចកាំជ្រួចដោយខ្លួនឯង ដើម្បីអបអរសាទរបុណ្យ 4th July នេះ។

- សូមកុំឲ្យក្មេងលេងឬអុចកាំជ្រួច
- មុននឹងអុចកាំជ្រួច សូមអានបំរាមនិងសេចក្តីណែនាំដែលមាននៅលើសំបកកាំជ្រួច ឲ្យបានច្បាស់លាស់សិន
- ពិនិត្យមើលកុំឲ្យមានមនុស្សនៅជិត មុននឹងចាប់ផ្តើមអុចកាំជ្រួច
- អុចកាំជ្រួចតែនៅលើកន្លែងណាដែលមានសភាពរាបស្មើល្អ, ហើយឆ្ងាយពីផ្ទះសម្បែង, ពុំមានគំនរស្លឹកឈើស្ងួតនិងគ្រឿងដែលអាចឆេះផ្ទុះនៅជិត។
- សូមកុំសាកអុចកាំជ្រួចណាដែលខូច ឬអុចពុំឆេះម្តងរួចទៅហើយ
- ជាពិសេស សូមសំរាំងទឹកមួយធុងនៅជិតខ្លួន ក្រែងលោត្រូវការចាំបាច់នៅពេលកាំជ្រួចឆេះពុំល្អ

ចំពោះពត៌មានបន្ថែមស្តីអំពី វិធីការពារកុំឲ្យមានគ្រោះថ្នាក់ដោយសារកាំជ្រួច សូមរិុបសៃរបស់ទីស្នងការការពារគ្រោះថ្នាក់ដោយការប្រើ ប្រដាប់ឬគ្រឿងផ្សេងៗនៃសហរដ្ឋ ហៅថា U.S. Consumer Product Safety Commission, www.cpsc.gov ។

*ពត៌មាននេះដកស្រង់នឹងបកប្រែចេញពីពត៌មាននៃក្រសួងសាធារណៈសុខាភិបាលប្រចាំ រដ្ឋម៉ាស្សាឈូសេត ដោយមណ្ឌលមេត្តាសុខភាពនៃមណ្ឌលសុខភាពសហគមន៍ក្រុងឡូវែល។*